នាងជឿថា សេចក្ដីស្នេហារមែងចំណុះទៅលើកាលៈទេសៈនិងពេលវេលា។ នៅរដូវរំហើយមនុស្សជាច្រើនមានអារម្មណ៍កក់ក្ដៅ ដូចជានោះជាវេលាពិសេសសម្រាប់សាងស្នេហាឬរៀបអាពាហ៍ពិពាហ៍កសាងអនាគតជាមួយគ្នា។

ចំណែកឯរដូវភ្លៀងធ្លាក់វិញ ដូចជាពេលមួយស្រងេះស្រងោច អារម្មណ៍នៃភាពឯកោបែកបាក់ នឹករឮកពិបាកពណ៌នាដែរ ឯខែកុម្ភៈនេះទៀតសោត....ហ៊ឹម អារម្មណ៍គ្មានសង្សារជាអារម្មណ៍មួយ....មិនចង់និយាយទេ!

ជាទូទៅសម្រាប់មនុស្សស្រីវ័យ២៥ឆ្នាំ អារម្មណ៍ប្ដូរមកនឹងនរច្រើនណាស់ ធៀបនឹងកាលនៅវ័យត្រឹម១៧ឆ្នាំ ដែលសូម្បីស្នាមញញឹមឬពន្លឺភ្នែកមួយ ក៏អាចចូលដល់បេះដូងនាងបាន។

ប្រសិនពេលវេលាដែលរស់តាមបែបមិនសូវដឹងក្ដី មិនខ្វល់ខ្វាយច្រើន រក្សាបានយូរមកទល់ឥឡូវហាក់ដូចជាសុភមង្គលពិតជាអមតៈ គ្មានអ្វីត្រូវបារម្ភពិតមែន ថែមទាំងបានធ្វើឱ្យបេះដូងក្លាយជាកក់ក្ដៅអចិន្ត្រៃយ៍... អ្វីៗតែងតែស្រស់បំព្រងភ្លឺស្វាង និងផ្អែមល្ហែម។

ទោះយ៉ាងណា ពេលវេលារមែងលាងជម្រះគ្រប់យ៉ាង មិនថារឿងល្អឬ ទុក្ខព្រួយ។ ជាមួយនឹងការគោះទ្វារជានិច្ចនៃថ្ងៃថ្មី រដូវកាលថ្មី នាងមានអារម្មណ៍ថា ចំណង់ចំណូលចិត្ត និងជម្រៅនៃសេចក្ដីស្រឡាញ់ដែលរស់រវើកនៅខាងក្នុងជម្រៅចិត្ត ចេះមានវ័យចាស់ឡើងៗ និងស្លាប់ទៅ មុនទាំងរូបកាយយើងដល់មរណៈផង។

ភាពធុញទ្រាន់ ជារឿយៗលេចមុខមកឱ្យឃើញ ឬលេងជាមួយឆាកជីវិតបន្តិចម្ដងៗ ភាពកក់ក្ដៅនៃស្នេហាចាប់ផ្ដើមរលាយបាត់បន្សល់ទុកនូវអនុស្សាវរខ្លះ ឯយូរបន្តិចទៀតសូម្បីអនុស្សាវរក៏ចាំមិនបាន។

«ញ៉ាំទៅ! នឹងអាលបានហៅកែវទីពីរ!»

«ហៅទៅ! ចាំបាច់អីចាំហៅតាមគ្នា?»

«ខុកថៃលនៅពេញកែវនៀក! ក្រែងអ្នកនាងធ្លាប់តែជាប់ចិត្តស្រាក្រឡុកនៅណេះនោះអ្វី?!»

«គ្មានអីស្អិតស្អេរទេ!»

«មិនសប្បាយចិត្ត? ព្រោះ Valentine?»

នាងដៀងមើលមកខ្ញុំហើយ។

មួយដង្ហើមទេ នាងលើកកែវពណ៌ស្វាយចាស់ ផ្សំឡើងពីជាតិសុរានិងផ្លែស្រកានាគខ្មែរពិតៗ មកក្ដឹកដាច់ភឹង។

ខ្ញុំបើកភ្នែកធំៗ.....ផ្អែកខ្នងនឹងបង្អែកវិញ....លែងហ៊ានក្អក.....

«ហៅ!»

នាងនិយាយខ្លី ធ្វើឱ្យខ្ញុំលើកចិញ្ចើមចង់សួរថា «ហៅអី?»

នាងមិនលេងទឹកមុខតាមខ្ញុំ ឬលេងជាកាយវិការទេ តែតបមកខ្ញុំស្រួយៗ៖

«ក្រែងចង់ហៅខុកថៃលថែមហ្អី?!»

ខ្ញុំមិងមាំង៖

«ហ្អំ! អូ...អូខេ! មិន....មិនបាច់សម្លុតក៏បាន!»

ងាកទៅរកអ្នករត់ដែលមានដោតកុលាបក្រហមនៅលើហោប៉ៅអាវ ខ្ញុំបក់ដៃ៖

«អូន! មកណេះសិនអូន! ចង់ Order ថែម!»

វដ្ដវបុណ្យនៃក្ដីស្រឡាញ់ឆ្នាំនេះ អាចចាត់ទុកថាជាចំណុចបញ្ចប់ទៅនូវអារម្មណ៍និងក្ដីស្រឡាញ់ទាំងអស់ដែលតែងតែបានបង្កករង់ចាំក្នុងជីវិតខ្ញុំ។

រាល់សុបិនបោកចិត្ត ការស្រមើស្រមៃទេវបុត្រក្នុងរឿងព្រេងនិទាន ឬប្រលោមលោកភាគទាំងអស់ត្រូវបានខ្ញុំដុតកម្ទេចនៅក្នុងបេះដូងចាស់មួយនេះហើយ។ សង្ឃឹមស្អែកថ្ងៃ១៥កុម្ភៈ ខ្ញុំផ្លាស់យកបេះដូងដែក ឬទឹកកក ឬជ័រក៏បាន មកដាក់ជំនួសវិញ។

ទោះយ៉ាងណាអ្នក SAD ពិតប្រាកដមិនមែននាងទេ គឺខ្ញុំ។

ខ្ញុំធ្លាប់មានសង្សារ៥នាក់ហើយ រយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ចំណែកនាងក្រោយពេលនាងបែកជាមួយគេ ៤ឆ្នាំមកនេះនាងគ្មានអ្នកណាទេ នៅតែនឹកគេ។ ខ្ញុំវិញមានសង្សារ៥នាក់មក ក៏រកមួយមកបណ្ដើរមិនបានដដែលនៅយប់នេះ។

អ្នកណាអ្នករងគ្រោះស្នេហ៍ឱ្យពិតទៅទៀត?

«យកអាពីរនេះ អូខេ...អរគុណ!»

ខ្ញុំញញឹមដាក់អ្នករត់តុហើយហួសភ្នែកចំបុរសម្នាក់ឈានមកដល់និងទាញកៅអីអង្គុយ។ ចម្ងាយប្រហែលជា៤ម៉ែត្រពីកន្លែងខ្ញុំ....

«អូយ! ប្រុសស្អាត!»

បើខ្ញុំមិនងាកទៅមើលគេម្ដងទៀត ទើបចម្លែក។

«មកតែម្នាក់ឯងទៀត?!» បេះដូងខ្ញុំប្រាប់ខ្ញុំ។

ជាបន្ទាន់ខ្ញុំបែរមករកនាង ហើយវាយចិញ្ចើមស៊ីញ៉ូភ្នែក ដើម្បីឱ្យនាងបានងាកមើលប្រុសស្អាតកណ្ដាលរាត្រីនៅក្រោយខ្នងខ្ញុំដែរ។ នាងសម្លឹងតាមការស៊ីញ៉ូនេះមែន ព្រោះថាយើងទាំងពីរមានម៉ូ! មិនបាច់ហាមាត់ប្រាប់គ្នាក៏យល់ចិត្តគ្នាបានដែរ។

សង្ឃឹមពេលឃើញប្រុសរាងខ្ពស់ មុខព្រងើយៗ ច្រមុះខ្ពស់ទល់ភ្នែកម្នាក់នេះ បេះដូងស្លាប់បាត់របស់នាង គ្រាន់នឹងមានរំញោចមកវិញខ្លះ តែ....កន្និកាបែរមកវិញ ញាក់ស្មាធ្វើហីដាក់ខ្ញុំ ថាជាសញ្ញា «មិនរវល់!»។

ខ្ញុំសម្លក់នាង ហ្វ្រីថែមពេបឱ្យមួយទៀត។ ស្អាតម្លឹងហើយ គេមិនទាក់ភ្នែក ទាក់បេះដូងខ្លះទេ? ៤ឆ្នាំហើយ! មិនចេះរេបេះដូង មកក្រឡេកមើលឃើញអ្នកផ្សេងផ្សើងខ្លះផង? គិតចាំអាយុ៦០ចាំគិតរកគូនឹងគេហើយមើលទៅ។

«អ្នករត់តុ!»

ខ្ញុំបើកភ្នែកព្រោះក្រឡង់ៗ.....ប្រភពសំឡេងលាន់មកពីតុមួយនោះ។ រូបស្អាត ជើងវែង ខ្នងត្រង់ ច្រមុះឌី ថែមទាំងសំឡេងពីរោះទៀត?

«បាទ!»

អ្នករត់តុដែលមានទងផ្កានៅហោប៉ៅប្រញិបប្រញាប់ប្រុងងាកដើរចេញទៅបម្រើអ្នកហៅម្នាក់នោះម្ដង ស្រាប់តែ....

«បងអ្នករត់តុ!»

សំឡេងស្រួយៗ មិនមែនរបស់ប្រុសស្អាតទេ គឺរបស់អាស្រីកន្និកាយើងនេះ។ នាងនឹកឃើញម៉េចបានចេញក្បួនមកបំបែកភាពស្ងប់ស្ងាត់ក្នុងបេះដូងខ្ញុំឱ្យរំជួយបាន?

ពេលខ្ញុំបើកភ្នែកធំៗ ឃើញនាងកាក់អ្នករត់តុមិនឱ្យទៅបម្រើប្រុសស្អាត នាងនៅធ្វើខិល ញញឹមឡើងខ្ចីតជាមួយទឹកមុខក្រឡង់ៗ។

«ខ្ញុំមានទាន់កុម្ម៉ង់ចប់ឯណា? ប្រញាប់ទៅណា?»

ម្រាមនាងកោងងរ លូកដៃចង្អុលហោប៉ៅអាវរបស់គេ៖

«ហើយ...ផ្កានៅហោប៉ៅហ្នឹង ពាក់យកឡូយឬមួយទុកជូនអ្នកណា? បើចិត្តល្អ សុំបានអត់? ណ៎ាមនុស្សអត់សង្សារ មានហ្ន៎ាគេជូន! ណ៎ាឱ្យមកណ៎ា»

ខ្ញុំបែកទ្រូងសម្លឹងស្រីស្រស់មិត្តខ្ញុំ ហើយរយើតៗទៅមើលប្រតិកម្មបុរសជើងវែង។

បានសម្រេចហើយនាង! គេនោះញឹមៗសម្លឹងមក....អូយ! ងាកមកមិនចំនៅឡើយផង ងាកប្រហែលតែ៣០ដឺក្រេ...បង្ហាញសម្រស់ឆ្លាក់បេះដូង.....គេគិតយ៉ាងណាបើអាកន្និកាខ្ញុំ ទើបនឹងត្រូវមួយកែវចេញក្រឡាស្រវឹងលេង....ញ៉ៅមែន....?

អ្នករត់តុញញឹមដកផ្កាហុចមកស្រីថ្លៃ.....រួចញញឹមសួរនាំ៖

«មានត្រូវការអីទៀតដែរអត់?!»

កន្និកាឃើញភ្នែកខ្ញុំសម្លក់ដែរ តែនាងធ្វើដូចមិនឃើញហើយសើចស្រស់ជាងមុនទៀត មាត់និយាយម្ញែកៗ៖

«ទៅចុះណ៎ាបង! បានផ្កាហើយ! លែងឃ្លានហើយ!»

អូយ! ថាចប់ខាំបបូរមាត់បានទៀត?

ខ្ញុំដកដង្ហើមវែងៗក្រពាត់ដៃសម្លឹងស្រីការបស់ខ្ញុំមិនមាត់ទេ ខណៈដែលចិត្តខ្ញុំពោរពេញទៅដោយសំណួរ៖«ឯងសំណាងហើយនាង! ឯងលេងប៉ះគេស្លូត! ទោះឯងខូចចិត្ត ក៏មិនត្រូវប្រថុយលេងអ៊ីចឹងដែរ ចុះបើគេចង់លេងវិញហើយក្រោកមកដល់ ឯងឱ្យយើងឯណេះគិតបែបណាហ្ន៎ានាង? ទោះណាយើងជាប្រុសមិនពិត តែយើងក៏ចេះអៀន ចេះភ័យ ហើយថែមទាំងគ្មានកម្លាំងការពារឯងទេ។»

ខ្ញុំគិតពាក្យទាំងនេះក្នុងចិត្តម្នាក់ឯង ត្រៀមស្រេចហើយថា ឱ្យតែអ្នករត់តុថយចេញបានឆ្ងាយបន្តិចទៅរកតុប្រុសស្អាតនោះឱ្យបាត់ទៅ នឹងអាលខ្ញុំឱនសួរនាំនាងពួកម៉ាក១០០ឆ្នាំម្នាក់នេះចេញម្តងថា«ស្រវឹងស្រាធុនអី?»។

ហៀបនឹងឱនទៅនិយាយស្ដីឱ្យ១០០ៗម្ដង ស្រាប់តែភ្នែកកន្និកាសម្លឹងអ្នកណាម្នាក់នៅក្រោយខ្នងខ្ញុំ។

មែន? គេនោះ.....ក្មាញ់អាកន្និកាយើងហើយ?...ក្រោកមកពីក្រោយខ្នងខ្ញុំ....ក្រោកមកសងសឹកមែន....

«តែពីរនាក់ទេ? សុំអង្គុយដែរ ខ្ញុំតែម្នាក់ឯង!»

មិនបានរំពឹងទុកមែន! ហើយ....រហ័សហួស! សំឡេងដែលពីរោះៗមុននេះ ឥឡូវឮមកក្បែរសែនក្បែរកតែខ្ញុំបិទមាត់ដែលហាជង្រុងនេះវិញមិនទាន់ផង កណ្ដាប់ដៃគេលូកទាញយកកៅអីមួយក្បែរដៃនិងអង្គុយមកភឹងកាត់ផ្ដាច់ចំកណ្ដាលពីរនាក់ខ្ញុំ។

ភ្នែកនាងបង្ហាញការខកចិត្តដែលមិនបានយកចិត្តទុកដាក់ថា «លេងសើចប៉ះគេអ្នកមែន»។

ខ្ញុំវិញធ្វើមាត់ស្ងៀមគ្មានសំឡេងទេ។ ដល់ពេលកន្និកាក្រឡេកមកខ្ញុំដូចជាស៊ីញ៉ូចង់ឱ្យខ្ញុំធ្វើអ្វីម៉្យាង....តែ....តើខ្ញុំធ្វើអីបានទៅ?

ងើបមុខមើលវឹប.....ប្រុសស្អាតពិតជាមានកែវភ្នែកខ្មៅហើយស្រឹមៗ ក្នុងជម្រៅជ្រាលជ្រៅពិបាកស្មានដឹងចិត្តគេពេកណាស់ ថាគេមកនេះ មកលេងឬមករករឿង.....?

គេមិនបានសម្លឹងខ្ញុំ ថែមមិនបានសម្លឹងនាង....តែគេសម្លឹងទងផ្កាដែលអាកន្និកាយើងទើបរកបានមក ហើយដាក់ផ្ដេកដាក់ចោលក្បែរកែវនាង....

«ខ្ញុំ....សួស្ដី ខ្ញុំឈ្មោះផល្លា! គេនេះឈ្មោះកន្និកា!»

នាងធ្វើភ្នែកបន្ទោសមួលក្លំ ទំនងខឹងដែលខ្ញុំមិនចាត់ការដេញភ្ញៀវគ្មានសំបុត្រអញ្ជើញម្នាក់នេះចេញថែមទាំងរាក់ទាក់ប្រាប់ឈ្មោះយើងទាំងពីរទៅគេទៀត។

«កាណាល់!.....ខ្ញុំ ខ្ញុំឈ្មោះកាណាល់!»

គេប្រាប់ខ្ញុំវិញដោយងាកមកសម្លឹងខ្ញុំត្រឹមតែមួយប៉ប្រិចភ្នែកប៉ុននោះ រីឯពន្លឺភ្នែកនៅសល់ប៉ុន្មានគេទុកឱ្យ.....នាង។

ខ្ញុំងើបមុខសម្លឹងប្រតិកម្មមិត្តគ្មានបេះដូងរបស់ខ្ញុំម្នាក់នេះ..... អាកន្និកាពិតជាត្រូវមួយកែវថែមគូល័រថ្ពាល់បានយ៉ាងធម្មជាតិ មិនបាច់ Make upទេ។

នាងធ្វើព្រងើយសម្លឹងទៅជម្រៅជាង៣០ជាន់ ពីក្រោម Sky Bar ទុកឱ្យប្រុសស្អាតញញឹមស្ទើៗតាមដៀងនាង។

មួយក្រឡេកដែលចិត្តរំពើត ទើបតែចាប់អារម្មណ៍ថា អាម៉ាកកន្និការបស់ផល្លាម្នាក់នេះ ស្អាតមិនអន់ទេ។ ជាមួយអាវវាលស្មាពណ៌ទឹកប៊ិកស្រស់ ហើយទម្លាក់សក់រលោងដូចសូត្រទៅម្ខាងស្មាទៀត.....ពិតជាឌឺដងភ្នែកប្រុសៗមិនធម្មតាដែរហ្នឹង....។

អ៊ីចឹងសោះបានគ្នាលេងសើចជាមួយអ្នករត់តុតិចតួច ស្រាប់តែអាចទាញយកខ្យល់មូសុងវស្សាមកបោកដល់តុនេះ មុនរដូវកាលកំណត់ពិតមែន។

«មិញ....ឮនិយាយពីផ្កា! គិតថា.....បើសុំជូនផ្កាពីរបីទង ព្រមយកដែរ?»

ភ្ញៀវដែលមកដោយមិនបានអញ្ជើញស្រដីយ៉ាងនេះទៀត មករកមិត្តសម្លាញ់ខ្ញុំ ធ្វើឱ្យខ្ញុំនៅឯណេះស្លុងភ្លឹប ទៅក្នុងការរបូតមាត់ឆ្លើយជំនួស៖

«យកៗៗៗ រឿងអីថាមិនយក?»

អូយ! របូតមាត់ជំនួសគេសាមីខ្លួនឡើងចចេចចចាចយើងនេះ។

ចេះឆ្លើយទៅរួចជំនួសចិត្តម្ចាស់គេ ដែលមិនទាន់និយាយអីមួយម៉ាត់ផង ឱ! អាផល្លាដ៏យ៉ាប់អ្វើយ។ ខ្ញុំបន្ទោសខ្លួនឯងក្នុងចិត្ត ដោយលើកក្រដាស់មកជូតមាត់ ខំរៀបឫកឡើងវិញ ខណៈអាស្រីយើងសម្លក់មកខ្ញុំសឹងដុតគ្នាបានទាំងរស់។

បញ្ចេញកំហឹងមកលើយើងក៏បាន! ឱ្យតែឯងរកបានគូគាប់ទ្រនាប់ចិត្តនាងនេះ!

ខ្ញុំគិតហើយសំងំបន្តជូតមាត់។ ដឹងអី សម្លក់ខ្ញុំនៅមិនអស់ចិត្តហើយក៏មិនព្រមឈប់ នាងបែរទិសទៅរកកំពូលអ្នកចែចង់ ផ្ដើមវាចាតបស្រួយៗ៖

«មានសង្សារហើយ!»

«គ្មានទេ! នាងគ្មានសង្សារទេ ទំនេរចិត្តកាយជាងបួនឆ្នាំហើយ!»

ខ្ញុំចង់របូតមាត់បែបនេះមួយប្រាវទៀតណាស់ តែម្ដងណេះនិយាយមិនចេញបានត្រឹមនៅស្ងៀមធ្វើមឹះៗ ចាំមើលថា តើខ្លាំងប៉ះខ្លាំង ប្រតិកម្មបក់បោកបានលឿនៗសាហាវៗប៉ុនណា?

ប្រុសស្អាតឮពាក្យសង្សារកាលណា ក៏សើចក្អាកក្អាយបំបែរមុខទៅសម្លឹងមើលគ្រប់ទិស។

ស្មានថា គេឮហើយនិងសើចអស់ចិត្តហើយក៏ឆាប់ក្រោករត់យករួចខ្លួន ដឹងអីដល់វេនគេសម្លឹងខ្ញុំនេះវិញម្តងហើយ។.....ខ្ញុំលេបទឹកមាត់ល្វីង...រកប្រាប់បន្តិច រកសំងំបន្តិច មិនដឹងគួរធ្វើម៉េចឱ្យសមសោះ....ចិត្តមួយចង់រកប្តីឱ្យពួកម៉ាកណាស់ តែក៏ខ្លាចពួកម៉ាកចងជើងព្យួរឡើងលើដែរ បានជាខ្ញុំនៅធ្វើឆ្លេឆ្លាសម្លឹងតុ មិនហ៊ានថែមថយសម្តី.....

«សើចអី?!»

គេសើចយូរពេកបានជានាងសួរ។

បួនឆ្នាំមុន កន្និកាទន់ភ្លន់និងរួសរាយ និយាយស្តីមិនរុញអ្នកណាទាល់ច្រកទេ នាងជាមនុស្សចេះគិតណាស់ហើយយល់ចិត្តអ្នកដទៃ។

ស្នេហាមកផ្អែមល្ហែមពេក នាងយកជាការណ៍ពេក ស្រឡាញ់មួយដឹងមួយពេក អ៊ីចឹងហើយបានជាពេលបែកគ្នាទៅធ្វើឱ្យឈឺចាប់យ៉ាងខ្លាំង។ បន្តិចម្តងៗអតីតរបស់នាងបានវិវត្តទៅជាស្នាមប្រេះជាច្រើនក្នុងបេះដូង ដែលទំនងជាជ្រៅនិងធំហួសពីការដែលអាចនឹងប្រើ «រនាបបាក់យករនាបជួស»។

ដូច្នេះ តើដល់ពេលណាកន្និកាអាចកសាងអារម្មណ៍ស្នេហាថ្មីមួយឱ្យខ្លួននាងបានទៅ បើនាងនៅតែមិនព្យាយាមកែសម្រួលស្នាមប្រេះឱ្យរលត់ទៅតាមពេលវេលាផង?

គេនេះឡូយហើយស្អិតទៀត នៅតែនាងមិនរង្គើចិត្ត មិនចង់ចាប់ឱកាសថ្មីអីបន្តិចសោះឬអ្វី?

«គេសើច ព្រោះឯងកុហក! ឯងគ្មានទាន់ស្រឡាញ់អ្នកណាផង បានសង្សារពីណាមក?»

ខ្ញុំនិយាយថាឱ្យអាសម្លាញ់គួរឱ្យអាណិតរបស់ខ្ញុំ។ ព្រោះតែរឿងអតីតដែលគ្មានតម្លៃមួយ កន្និកាបានបោះបង់ខ្លួននាងចោលហើយ បើខ្ញុំបោះបង់នាងចោលទៀត នាងបានអីទៅ?

បានជានិយាយហើយ មេឃបាក់សង្កត់ក៏បាក់ទៅ....ខ្ញុំសម្លឹងទៅគេនេះភ្លាម។ បំណាច់តាំងចិត្តនឹងធ្វើមេអណ្តើក ក៏ត្រូវធ្វើឱ្យដល់ចុងបញ្ចប់ឱ្យដូចពាក្យចាស់ថា នឹងលូកប្រហុក....អុះ ខ្ជិលនិយាយ....គេមិនមែនប្រហុកទេ អាចជាជង្រុកស្រូវផងដឹង បើពិនិត្យតាមកាយវិការនិងរបៀបតុបតែងខ្លួនសាមញ្ញៗ តែ Cool Cool របស់គេ.....

គេញាក់ស្មាញញឹមពេញចិត្តនឹងមាត់ចប្រចែតរបស់ខ្ញុំ ខណៈអាកន្និកាលើកទងផ្ការបស់នាងគប់ខ្ញុំ...

«ចង់បានសង្សារហ្មែន យកទៅ! យកទៅ!»

សូម្បីក្រដាសជូតមាត់ក៏នាងប្រមូលមកខ្ទប់ខ្ទុំម្ដងមួយៗរហូតអស់ពីតុ ខ្ញុំនៅមិនខ្វីគេចទៅណា....

«ស្រីៗល្អៗដូចគេ មានការរំពឹងទុកខ្ពស់បន្តិច! ញ៉ែគេទៅ ខ្ញុំអនុញ្ញាត!»

ខ្ញុំថាមួយៗទៅកាន់ប្រុសស្អាត ទាំងមិនដឹងផងថា ខ្លួនឯងកំពុងធ្វើអ្វីឱ្យប្រាកដ! តែអ្វីដែលប្រាកដនោះគឺ ខ្ញុំពិតជាមិនចង់ឆ្នាំក្រោយឃើញកន្និកាបែបនេះទៀតទេ។

បុរសដកដង្ហើមវែង.....មិនដឹងជាគេសប្បាយចិត្តឬអត់ឡើយ តែចិត្តខ្ញុំសប្បាយណាស់ ពេលឃើញវត្ថុមានរបស់គេមកបានដូចទេពនិមិត្តក្នុងរាត្រីនេះ គឺចូលមកក្នុងជីវិតរបស់កន្និកា។

ខ្ញុំសម្រេចចិត្តក្រោកចោលស្រីឆ្នាស់តែគួរឱ្យស្រឡាញ់ម្នាក់នេះហើយ។

ម្ដេចឡើយគ្រាន់តែក្រោកឡើងមកភ្លាម បេះដូងនេះដូចជាជ្រុះបាត់អ្វីម្យ៉ាង? អ្វីមួយដ៏សែនមានតម្លៃ ខ្ញុំបានទុកនៅទីនេះឱ្យប្រុសស្អាតម្នាក់ទៀត ដែលខ្ញុំមិនដែលស្គាល់សោះ.....

«ឈប់ភ្លាម ផល្លា! ឯងទៅណា?»

នាងសួរមកធ្វើឱ្យខ្ញុំកាត់ចិត្តខាំមាត់ចាកចេញ.....

«យើងទៅហើយ! មានរវល់!»

ខ្ញុំបែរខ្នងដាក់គេ តែចិត្តខ្ញុំដូចជាកំពុងតែឈឺនិងស្រាលឡើងៗដោយគ្មានមូលហេតុ។ បើមិនសប្បាយចិត្ត បើ Sad បែបនេះ ហេតុអ្វីបានជាខ្ញុំចាកចេញពីគេ? ចម្លើយគឺងាយរកណាស់ ព្រោះខ្ញុំចង់ឃើញគេមានសង្សារ.....

«មកវិញភ្លាម! ផល្លាឡប់! មកវិញឮអត់?»

នាងក្រោកមកដែរ ដោយបោះបង់ចោលបុរសដ៏សង្ហារនៅកណ្ដាលស្ដាយបារ ដែលពេញប្រៀបទៅដោយពិដោរផ្កាកុលាប ឯគូសង្សារគ្រប់ជ្រុងចោលភ្នែកគ្រប់គ្នាសម្លឹងមកពួកយើង ដូចជាខ្ញុំនេះកំពុងតែផ្ដាច់ស្នេហ៍ពីនាង។

«ហើយ....កើតរោគចិត្តស្អី ឯងហ្នឹងហ្អា៎ ក្រែងអ្នកបបួលយើងចេញមក ឯងរវល់ស្អីគេ?»

កន្និកាសួរបែបនេះឮៗ ពេលនាងតាមខ្ញុំមក។ ដល់នាងមកក្បែរធ្វើឱ្យខ្ញុំឈប់ដំណើរបែរក្រោយសម្លឹងនាង។ ភ្លាមនោះម្រាមដៃទាំងដប់របស់នាងលូកមកចាប់ក្ដោបបាតដៃឆ្វេងខ្ញុំ។

«ឯងទៅផឹកស្រាអីបានជាឆ្កួតៗបាន? ឱ្យលុយឱ្យគេសិនទៅ ប្រាប់តាំងពីនៅខាងក្រោមថាយើងមិនបានយកលុយមកទេ!»

ខ្ញុំដៀងភ្នែកសម្លឹងឃើញអ្វីម៉្យាង សែនស្រពោននៅក្នុងជម្រៅកែវភ្នែកគេ។ សាជាថ្មីខ្ញុំដៀងភ្នែកមួយជុំមើលមនុស្សគ្រប់គ្នាដែលគេមានគូ និងចុងក្រោយខ្ញុំបែរទៅសម្លឹងប្រុសស្អាតដែលកំពុងតែអង្គុយនៅនឹងកន្លែងចាស់របស់យើង។

ម្នាក់នោះអង្គុយឱនចុចទូរសព្ទ ដូចជាគេរង់ចាំឱ្យនាងដូរចិត្តឬចាំឱ្យខ្ញុំដឹកដៃនាងទៅឱ្យគេ?

ខ្ញុំបន្ទោសក្នុងចិត្តម្នាក់ឯងស្ងាត់ៗ.....អ្ហែងមិនក្រោកមកតាមគេអាប្រុសស្អាត?

សំឡេងនាងលាន់មកថែមឡើង៖

«គិតម៉េច បានចង់ទុកខ្ញុំឱ្យទៅគេម្នាក់ហ្នឹងហ្អា? ផល្លាឯងស្គាល់គេពីពេលណាមក?»

ខ្ញុំបែរមកសម្លឹងនាង ខំធ្វើចិត្តនិងខំកាត់ចិត្ត ហើយនិយាយឡើងថា៖

«យើងមិនដឹងទេនាងកន្និកា! ប៉ុន្តែ....ឯង....ត្រូវតែរស់ឡើងវិញ! ឯងរស់ជាថ្មីៗ ធ្វើមនុស្សស្រីនឹងគេទៅ....!»

និយាយបានប៉ុណ្ណេះក៏លែងនិយាយចេញ ព្រោះភ្នែកនឹងភ្នែកពួកយើងបានវាក់វិនគ្នា។ ពន្លឺភ្នែកកន្និកា បានបង្អាក់បាននូវរាល់អ្វីៗដែលខ្ញុំប្រុងនិយាយ។

«អ្ហះ?....យើងស្លាប់ស្អីឯង? រស់ឡើងវិញស្អីគេ? ឯងហ្នឹងហើយដែលស្លាប់ ផល្លាឡប់! អ្នករត់តុ! មកណេះ!»

ស្រីស្អាតលូកដៃមកក្នុងហោប៉ៅខោរបស់ខ្ញុំ ទាញយកកាបូបលុយខ្ញុំទៅទូទាត់ប្រាក់ឱ្យគេ ហើយរួចទើបទាញអូសដៃខ្ញុំបណ្តើរទៅកាន់ជណ្តើរយន្ត។

«ពូកែណាស់ ឱ្យយើងធ្វើស្រីផង ចុះឯង អ្ហះ? ឯងព្រមធ្វើប្រុសទេ?»

សូម្បីហោប៉ៅខ្ញុំនេះ ខាងណាដាក់កាបូបលុយក៏គេដឹង! សូម្បីតែខ្ញុំគិតអីទាំងមិននិយាយចេញផងគេក៏ប្រហែលជាអាចដឹង។ មាត់ខ្ញុំខំប្រណាំងនិយាយបន្លប់នាង៖

«ហើយ....គេនៅអង្គុយនៅហ្នឹងចាំឯង....ចេញមកធ្វើស្អី? ចំណីនៅមាត់ ថាសគេលើកមកដល់តុហើយនាង? អូខេ ហោចណាស់ ត្រលប់ទៅឱ្យលេខទូរសព្ទគេមួយទៅនាង?»

«បានហើយ ឈប់ឆ្កួត!»

ទ្វារជណ្ដើររបើក។

គេជេរខ្ញុំបែបនេះដោយរុញខ្ញុំចូលក្នុងជណ្ដើរយន្ត។ ខ្ញុំឈរផ្ទាំងៗពីក្រោយខ្នងគេ ឃើញសាច់សម៉ដ្ឋក្រហមព្រឿងៗរបស់នាងនៅក្នុងអាងវាលខ្នង។ យប់នេះកន្និកាតែងខ្លួនស្អាតណាស់ ក្លិនគេក្រអូបប្រហើរពេលនៅកៀកគ្នាបែបនេះ....សោកស្ដាយដែរដែលតុបតែងខ្លួនបានស្អាតខ្លាំង ហើយទេវបុត្រក៏ចុះមកដល់តុស្រាទៀត....គេមិនព្រមចាប់ឱកាសបែរជាឆ្លេឆ្លាចេញមកជាមួយខ្ញុំ.....

ខ្ញុំហាមាត់ឡើងប្រុងថាឱ្យមិត្ត ស្រាប់តែត្រូវហារច្រងាងបែបនោះទៅ ដោយសារតែជណ្ដើរយន្តរបើក លេចចេញមុខប្រុសសង្ហារាងខ្ពស់ជ្រងោម្នាក់នោះ......

គេពិតជាសឿងគួរសម.....

ក្រោកមកតាមទៀត? គេឈរនៅទីនោះ សម្លឹងមកកាន់កន្និកាដោយក្រសែភ្នែកស្រទន់....បុរសនេះនៅមិនអស់ចិត្តនឹងសម្រស់របស់មិត្តខ្ញុំនៅឡើយទេ....

«ប្រញាប់ទៅណាម៉េះ? លេងសើចដាក់គេហើយក្រោកចោលចឹង?»

ខ្ញុំរវើ្ភកចេញទាំងដង្ហើមហត់អួសៗ....តើខ្ញុំជាខ្មើយដែលចាញ់ស្នេហ៍ចរិតឡូយមួយបេនរបស់ប្រុសម្នាក់នេះ ឬខ្ញុំចាញ់ស្នេហ៍អ្នកណាឱ្យប្រាកដ....?

«ហើយសើចលេងស្អី?»

កន្និកាសួរវិញទាំងសំឡេងខឹង។ នាងគួរតែដឹងថា គេនេះក្លាហានគ្រាន់បើណាស់ ព្រោះមានតែម្នាក់ឯងក៏ហ៊ានមកតាមញ៉ែស្រីដល់ជណ្ដើរយន្តនេះទៀត? ថាសឿង សឿងហើយ!

«នេះសង្សារខ្ញុំ!»

នាងថាស្រួយៗ ហើយបែរមកឱបត្រកងដៃឆ្វេងរបស់ខ្ញុំពេញទ្រូងទ្រលុកទ្រលន់របស់នាង គឺឱបសឹងតែស្បែកនឹងស្បែក ពួកយើងរលាយចូលគ្នាជាមនុស្សតែម្នាក់បាន។

ធ្វើទៅកើត?

ខ្ញុំបើកភ្នែកធំៗសម្លឹងតបទៅភ្នែកប្រុសស្អាតដែលដៀងមកខ្ញុំ!

ខ្ញុំនេះមើលទៅមិនមែនប្រុសពិតទេ ចុះម៉េចក៏......

បេះដូងខ្ញុំកំពុងតែកក់ក្ដៅដោយសារតែស្រីស្អាតនិងប្រុសសង្ហាប៉ះគ្នានៅនឹងមុខ នៅនឹងមាត់ ហើយទឹកមុខគេដែលតាមមើលកន្និកា មិត្តភក្តិរបស់ខ្ញុំក៏គួរឱ្យស្រៀវស្រើបខ្លាំង ស្រាប់តែនាងប្រើស្ទីលមកឱបខ្ញុំស្អិតជាប់ដើមទ្រូង ខ្ញុំភាំងដូចរលាយអស់យុទ្ធសិល្ប៍......

ច្រើនឆ្នាំមកនេះ.....ខ្ញុំតាំងខ្លួនជាភេទទីបី មានសង្សារប្រុសៗរាប់ភ្លេច ទោះបីថាគ្មាននរណាម្នាក់ជាប់លាប់មកទល់ឥឡូវ ក៏ខ្ញុំមិនដែលសាកស្រឡាញ់មនុស្សស្រីដែរ។

ប៉ុន្តែ.....នៅពេលមួយនេះ ពេលដែលគេចាប់ខ្ញុំយកធ្វើជាឧបករណ៍គេចពីការតាមញ៉ែរបស់បុរសរាងខ្ពស់ ខ្ញុំមិនដឹងកើតអី បានជាក្លាយគល់ឈើលែងនិយាយស្រីចេញ ធ្វើភ្នែកភ្លឹះៗកណ្ដាលជណ្ដើរយន្តដែលគាំង.....

«ហ្នឹងហើយសង្សារខ្ញុំ! ចេះខ្មែរអត់? និយាយពីរដងហើយណាំ!»

កែវភ្នែកប្រុសស្អាតដែលសម្លឹងមកខ្ញុំប្រហែលជាងឿងឆ្ងល់ថា សង្សារអីដែលយកមនុស្សស្រីមកទុកប្រុសផ្សេងញ៉ែ.....?

«ចេញ! តិចហៅសន្តិសុខ!»

កន្និកាគំរាមគេនោះទៀត ធ្វើឱ្យខាងប្រុសរបូតដៃពីកុងតាក់ ទ្វារក៏បិទទៅវិញយឺតៗ។

ពីរនាក់យើងចុះក្រោមសន្សឹមៗហើយ ឯខ្ញុំវិញចាប់អារម្មណ៍ថា ឮស្នូរបេះដូងនាងដែលនៅតែភ័យលោតក្តុកក្តាក់។

«លែងដៃបានហើយ!»

ខ្ញុំនិយាយនេះទាំងដើមបេះដូងលោតខុសចង្វាក់។

«មិនលែង!»

នាងថាមកវិញភ្លាម ហើយតែពីរម៉ាត់នេះគត់។

គេស្រវឹង? ខ្ញុំឈ្ងោកមើល......សក់គេរលោងរលូន ចង់តែស្ទាបគីនៅក្បែរទ្រូងខ្ញុំបង្អើយ។ ឯដៃគេតោងខ្ញុំជាប់សឹងដាច់ផ្ងារទាំងអស់គ្នាបើខ្ញុំជំហរទន់.....

«ឆ្ងល់ឯងណាស់?» ខ្ញុំថាឱ្យគេរអ៊ូៗ

«ឆ្ងល់ស្អី?» គេតបវិញរអ៊ូៗដែរ។

«មនុស្សស្អាតសង្ហា លើកថាសមកដល់ចំពោះមុខហើយ ឯងមិនចេះស្រឡាញ់?»

«ចុះខ្លួនឯងវិញ?!» នាងមិនបង្អង់ទេ គឺសួរខ្ញុំគ្មានដាច់ពាក្យដូចគ្នា។

«យើង? យើងជាតិនេះឆាចោលហើយ! រឿងខ្លួនមិនគិតទេស៎ មកគិតអីរឿងអ្នកដទៃ? កំព្រាបេះដូងយូរប៉ុនណាហើយ? អត់ផ្កានឹងគេប៉ុន្មានValentineហើយអ្ហះ?»

«មកពីឯង! មនុស្សកំណាញ់ឯងនេះ ម៉េចឯងទិញផ្កាឱ្យយើងមិនបានអ្ហះ?»

គេទម្លាក់ដៃចោលខ្ញុំ ខណៈបេះដូងខ្ញុំហាក់របូតចុះដល់ជាន់ក្រោមមុននឹងជណ្ដើរយន្តចុះទៅដល់ទៀត។

«ច្រើនឆ្នាំមកនេះ យើងខំស្លៀកពាក់ស្អាតបាត តែងខ្លួនឡូយៗ ទៅអប់សក់ តែងខ្លួនរាប់ម៉ោង រាល់តែ Valentine! តែឯងនេះ ផល្លាឡប់! ឯងមិនដែលមើលឃើញទេ ឯងផ្កាមួយទងក៏កាន់មកមិនរួចដែរ មនុស្សចង្រៃ! ចង់ឃើញយើងកាន់ផ្កា ម៉េចឯងមិនទិញមកឱ្យយើង? អ្ហះ យើងស្អប់ឯងណាស់!»

គេងាកមកវាយទះទ្រូងនិងដើមដៃខ្ញុំ ខណៈខ្ញុំនៅឈរធ្មឹងបណ្ដោយឱ្យគេធ្វើតាមចិត្ត។

ទ្វាររបើក។ គ្រប់គ្នាដែលចាំជណ្ដើរចំហមាត់សម្លឹងមកពួកយើង.....ដូចភ្ញាក់ផ្អើល....គូស្នេហ៍មួយគូឈរមុខគេ ថយក្រោយខ្លាចពួកខ្ញុំឈ្លោះគ្នាខ្ទាតកំហឹងត្រូវពួកគេដឹង?

....ចាប់អារម្មណ៍ថាស្រីៗទាំងអស់ដែលកាន់ដៃគូស្នេហ៍របស់គេ សុទ្ធតែពាក់អាវវ៉ាលស្នា ខ្លះចោមពុម្ពតែម្ដង......

នឹកឃើញឡើងវិញ.....បួនឆ្នាំហើយ....បុណ្យសង្សារបួនដងហើយ! កន្និកាពាក់អាវមិនដែលមានស្នាទេបើមិនសំយ៉េះខាងឆ្វេងក៏ខាងស្ដាំ ឬអត់ស្នាទាំងសងខាងតែម្ដង!

យើងចំណាយពេលជាមួយគ្នា៤ Valentinesហើយ.....?

ខ្ញុំភាំងក្នុងជណ្ដើររហូតដល់គូស្នេហ៍នានាចាំយូរពេក គេមិនឃើញខ្ញុំចាកចេញទៅតាមខាងស្រី គេក៏ទាញគ្នា ដើរចូលមកសយញ៉យ ម្ដងមួយគូៗ.....

ខ្ញុំដូចស្វាងចេញពីភាំងៗនឹកឃើញរឿងទាំងឡាយ......

«កន្និកា!»

ខ្ញុំរត់តាមគេហើយស្រែកហៅគេផង។

មកដល់ចំណតឡាន ខ្ញុំឃើញគេឈរក្បែរនោះ.....

ខ្ញុំស្រូតចុចបើកទ្វារឱ្យ ចំណែកគេចូលទៅអង្គុយ។ ខ្ញុំក៏ចូលទៅអង្គុយដែរ ហើយថយឡានចាកចេញដោយស្ងៀមស្ងាត់...រាជធានីភ្នំពេញយប់នេះចម្លែកណាស់.....ជាលើកទីមួយដែលយើងអង្គុយក្នុងឡានក្បែរគ្នាហើយស្ងប់ស្ងាត់ដល់ម្លឹង...ទីបំផុតគេលើកដៃជូតទឹកភ្នែក....ទ្រូងខ្ញុំក៏រហែកទៅតាមដង្ហើមតឹងៗរបស់គេ.....

«សុំអង្វរណា៎ ឯងកុំយំ!»

ខ្ញុំនិយាយទាំងពិបាកចិត្ត! គេរឹតតែយំឡើង។

«ទៅ! ថ្ងៃក្រោយយើងសន្យា....ឈប់រកសង្សាររឱ្យឯងទៀតហើយ! មើលយើងចុះ យើងក៏គ្មានអ្នកណាដែរ តែយើងខ្វិលយំណាស់! យប់នេះ ជាយប់ Romantic ឯងត្រូវមានភ្នែករឹងជាងយើងដែលជាខ្ទើយ!»

នាងងាកមកសម្លក់ខ្ញុំ ធ្វើឱ្យខ្ញុំងាកចេញលែងនិយាយ ស្រាប់តែនាងថាមកស្រួយៗ៖

«ឯងមិនមែនខ្ទើយទេ! ឯងបារម្ភខ្លួនឯងមិនអាចរស់នៅជាមួយមនុស្សប្រុសទាំងនោះបានមែនទេបានជាឯងមិនដែលជាប់លាប់? ព្រោះបេះដូងឯងនៅទីនេះ! ឯងតែងតែនៅជាមួយយើង រាល់ថ្ងៃបុណ្យសង្សាររតើមានមនុស្សណាគេទ្រាំទទួលយកឯងជាសង្សារ បើ Valentine ឯងមកដឹកយើងរាល់តែលើក?»

ខ្ញុំមិនមាត់ទេ។ ច្រើនឆ្នាំមកនេះ ខ្ញុំស្មានតែគេមិនដែលបំភ្លេចសង្សាររចាស់របស់គេ ដែលត្រូវខ្ញុំដាល់ចំកណ្តាលមុខ នៅថ្ងៃដែលយើងបានដើរទៅជួបគេកំពុងបណ្តើរស្រីថ្មី កាលហ្នឹងត្រូវសងជំងឺចិត្តគេជាង១000ដុល្លារ។

តាមពិតអាកានៅរង់ចាំខ្ញុំ......ឱ្យទទួលស្គាល់ខ្លួនឯង ...

នាងនិយាយខ្សឹកខ្សួល៖

«ចាំអត់? ឯងនៅចាំទេ? កាលថ្នាក់ទី៨ ដែលលេងផ្លោះរបងមករកខ្ញុំនៅពេលដែលខ្ញុំដួល! ឯងក៏រយះជើងនៅព្រោះតក់ក្រហល់ពេក! ចាំអត់នៅថ្នាក់ទី១២ ថ្ងៃដែលយើងប្រលងបាក់ឌុប ឯងខំរត់មករកយើងយ៉ាងលឿនទាំងធ្វើរបស់ឯងមិនល្អ ហើយបាននិទ្ទេសចាញ់យើងទាំងដែលយើងមិនពូកែដូចឯងហើយឯងគិតពីយើងរហូតមក មិនថាអាវ Hoody ដែលយើងនៅចង់បាន ឯងសន្សំលុយទិញប្រេនៗមកឱ្យយើង! ថ្ងៃយើង Dating សង្សារសំអុយម្នាក់នោះ យប់ម៉ោង៨ ឯងឆាតមកខ្ញុំរហូត តាមខ្ញុំ ខ្លាចទៅ

ណាផ្គេសផ្គាសជាមួយគេ ឯងខ្លាចខ្ញុំត្រូវគេបោកមែនអត់? ហើយបើឯងស្រឡាញ់ខ្ញុំម្លឹងៗ ម៉េចបានជាចេះតែចង់ណែនាំយើងឱ្យប្រុសផ្សេង?»

«យើងមានសិទ្ធិអីទៅស្រឡាញ់មនុស្សស្រី! ឯងមើលយើងចុះ!»

ខ្ញុំតបវិញដោយរលីងរលោង។ ខ្ញុំប្រហែលមិនស្គាល់បេះដូងខ្លួនឯងច្បាស់ដូចនាងទេ។ នាងមើលខ្ញុំឃើញច្បាស់ដូចថ្ងៃទៅហើយ.....

«ឯងកុហក! ឯងមិនស្គាល់ខ្លួនឯងច្បាស់ ហើយឯងគេចវេះ? ធ្វើចឹងដើម្បីស្អីទៅ?»

«ព្រោះខ្ញុំគិតថា ឯងជាមិត្តរបស់ខ្ញុំ ខ្ញុំចង់ឱ្យឯងមានជីវិតល្អមួយ!»

«ជីវិតយើងល្អតាំងពីយើងបានស្គាល់ឯង! យើងមិនដឹងទេ សង្សារឯងម្នាក់ៗមកនិយាយជាមួយយើងថា គេទ្រាំឯងមិនបាន ព្រោះឯងនៅជាមួយគេតែឯងតែងគិតពីយើង! ឯងថាខ្លួនឯងជាខ្ទើយ តែចិត្តឯងមានមនុស្សស្រី ហើយមានតែម្នាក់គត់តាំងពីក្មេងដល់ពេលនេះ! ឯងនៅក្បែរយើងគ្រប់ពេលវេលាគ្រប់ទីកន្លែង! សង្សាររបស់យើងបែកពីយើង មិនមែនដោយសារគេមិនស្រឡាញ់យើងទេ តែគេប្រចណ្ឌឯងដែលជាស្រមោលអន្ទោលតាមយើង ហើយចុងក្រោយទៅគេទទួលស្គាល់ថា គេមិនបានស្រឡាញ់យើងស្មើនឹងឯង.....!»

ទឹកភ្នែករបស់ខ្ញុំស្រក់ចេញមកដោយស្ងប់ស្ងាត់។ កន្និកាកំពុងលាតត្រដាងនូវរឿងអាថ៌កំបាំងមួយរវាងយើងពីរនាក់ ដែលយើងនៅក្បែរគ្នារាល់ថ្ងៃ ប៉ុន្តែមិនអាចបើកវាចេញ។

ពិតណាស់ គេជាមនុស្សដ៏សំខាន់ក្នុងជីវិតខ្ញុំ។ ពេលលើកម្ហូបឆ្ងាញ់មកញ៉ាំ ខ្ញុំនឹកដល់គេ ពេលរៀបទៅធ្វើការខ្ញុំនឹកគេ ចេញមកវិញខ្ញុំឆ្ងល់ថាគេនៅឯណា...មុនគេងខ្ញុំឈៃតគេចូលគេងខ្ញុំបារម្ភពីគេក្រោកពីគេងនឹកចង់ដឹងថា គេស្លៀកពាក់អីនៅថ្ងៃថ្មី....

«ហើយ...ផ្កានៅហោប៉ៅហ្នឹង ពាក់យកឡូយឬមួយ ទុកជូនអ្នកណា? បើចិត្តល្អ សុំបានអត់? ណុ៎ះមនុស្សអត់សង្សារ មានហ្នុ៎ះគេជូន! ណុ៎ះឱ្យមកណុ៎ះ»

សម្តីគេឌឺអ្នករត់តុនៅខាងលើ តាមពិតគេឌឺខ្ញុំ....ព្រោះឆ្នាំនេះខ្ញុំក៏អត់ទិញផ្កាមួយឱ្យដដែលទៀត...គេអន់ចិត្តគេអកស្រាបញ្ឈើខ្ញុំ មួយកែវដាច់ប៉ិត....

ខ្ញុំដៀងភ្នែកសម្លឹងសម្រស់របស់គេនៅក្បែរដៃ.....គេជាស្រីស្អាតណាស់ មិនធម្មតាទេ អ៊ីចឹងហើយបានជាអាគាត់រាងខ្ពស់នៅស្តាយបារនោះ ត្រូវមួយព្រួញស្នេហ៍តាមមកដល់ជណ្តើរយ៉ាងស្អិត....

«ទុកថាបេះដូងយើងបារម្ភពីឯង យើងគិតឯងជាងអ្នកណាទាំងអស់! តែឯងឃើញហើយ! ខ្ញុំជាមនុស្ស......ដែលមិនដែលស្រឡាញ់ស្រី.....មិនដែលទាំងទៅប៉ះស្រីណាម្ដងផង....យើង....ចុះ»

នាងតបមកវិញ៖

«ឯងគិតថាខ្ញុំខ្វល់!»

ខ្ញុំដៀងភ្នែកសម្លឹងគេ។

ពិតណាស់ខ្ញុំឈឺច្រើនដងហើយ ពេលដែលឃើញគេSad ហេតុអីខ្ញុំមិនឆ្ងល់ខ្លួនឯង។ ខ្ញុំជាមនុស្សគ្មានយែនឌ័រទេ ខ្ញុំគិតថាខ្លួនខ្ញុំស្រឡាញ់ប្រុស តែខ្ញុំបានស្រឡាញ់ស្រីម្នាក់ជាយូរណាស់មកហើយ.....ស្រឡាញ់ដោយគ្មានលក្ខខណ្ឌ និងស្រឡាញ់ដោយស្មោះអស់ពីបេះដូង.....

សេចក្ដីស្នេហាគឺការដែលមានអារម្មណ៍ពិសេសពេលនៅជាមួយមនុស្សម្នាក់ ហើយចង់ឃើញគេសប្បាយចិត្ត។ សូម្បីតែមិនដែលគិតទៅដល់ការរួមភេទជាមួយគេ តែខ្ញុំតែងតែទុកគេដូចជាខ្លួនខ្ញុំ ចង់ឃើញគេបានស្អាត ចង់ឃើញគេបានល្អ ចង់ឃើញគេឡូយឆាយ ប្រៀបជាមួយស្រីៗឯទៀត។

ពេលវេលាដែលចំណង់ចំណូលចិត្តខ្លាំងអំពីជីវិតខ្លួនឯង ចាប់ផ្ដើមថយចុះ ដោយប្រើពេលវេលាសឹងទាំងអស់ គិតអំពីគេ។ មនោសញ្ចេតនាពិតប្រាកដមួយនៅកំដរខ្ញុំជានិច្ច ដែលក្នុងនោះតែងមានវត្តមានគេជានិច្ចដូចគ្នា។ អារម្មណ៍យកចិត្តទុកដាក់ និងស្រឡាញ់ឈឺឆ្អាលគេយ៉ាងខ្លាំង គិតតែធ្វើបែបណាដើម្បីឱ្យគេសប្បាយចិត្ត បានបង្កើតជាបញ្ហាមួយឱ្យពួកយើង គឺនាងក៏មិនអាចមានអ្នកណា ខ្ញុំក៏មិនជាប់លាប់ជាមួយអ្នកណា។

ខ្ញុំមិនដែលផ្ដល់អំណោយបាច់ផ្កាដ៏ស្រស់ស្អាត ដូចជាគូស្នេហ៍ផ្សេងៗបាននឹងនិយមធ្វើ តែខ្ញុំបានឱ្យបេះដូងខ្ញុំទៅគេយូរណាស់មកហើយ។

ពេលវេលានិងបណ្ដារឿងរ៉ាវដែលពួកយើងបានឆ្លងកាត់ មនុស្សតែងផ្លាស់ប្ដូរ និងភាពចាស់ទុំចិត្តគំនិត ធ្វើឱ្យគេមានទស្សនៈជាក់លាក់ឡើងវិញអំពីរឿងទំនាក់ទំនងដៃគូ ដូច្នេះហើយគេសួរខ្លួនគេថាខ្ញុំជាអ្វីនៅក្នុងជីវិតរបស់គេ។

«ខ្ញុំដឹងជាបណ្ដើរៗថា ថ្ងៃណាក៏ខ្ញុំនឹកដល់ផល្លាឯង! ខ្ញុំរស់នៅពិបាកផ្លាស់ប្ដូរណាស់ពេលគ្មានផល្លាឯង! រាល់ពេលឯង Dating មនុស្សប្រុស យើងសប្បាយចិត្តតែដូចចង់ផ្ដើមថប់ដង្ហើម និងចុះខ្សោយអារម្មណ៍បន្តិចម្ដងៗពេលដឹងថា ឯងនៅជាមួយគេ! ក្រោយមកយើងដឹងថា យើងប្រចណ្ឌឯង យើងច្រណែនពិតមែន!»

នាងនិយាយអស់ហើយនូវអ្វីៗដែលខ្ញុំចង់និយាយ។ ខ្ញុំកើតមកជារូបកាយមនុស្សប្រុស តែមានមាត់មួយឥតសូវមានគម្រប និយាយច្រើន មានគំនិតមួយ ល្ងិតល្ងន់ គិតម្រេចខ្ទឹម ខ្មៅចខ្ទីរហូតច្រលំថាខ្លួនខ្ញុំជា«ភេទផ្សេង»ទាំងដែលចេះស្រឡាញ់គេ តាំងពីរៀនថ្នាក់ទី៨។

ខ្ញុំមានមិត្តប្រុស៥នាក់ តែបេះដូងគិតមិត្តប្រុសទាំងនោះតិចជាង«គេ»នេះជានិច្ច ។ ម្តងៗមិត្តប្រុសខឹងដែលខ្ញុំនិយាយតែអំពីមនុស្សស្រីម្នាក់ឈ្មោះ«កន្និកា» ពួកគេឌឺខ្ញុំថា«នឹកណាស់ម៉េចមិនទៅស្រឡាញ់នាងហ្នុងទៅ»។

ភាពខុសគ្នានៃការយល់ឃើញនិងសកម្មភាពបេះដូង បានស៊ីពេលវេលារបស់យើងយូរមកហើយ....

ខ្ញុំដឹងថាពេលនេះខ្ញុំត្រូវទៅណា....ម៉ោងទើបតែ៨ជាងទេ...មានហាងផ្កានៅបើកលក់ទៀតអត់ហ្ន៎.....

អ្នកណាដឹងជួយឈៃតមកខ្ញុំផងបានអត់....ខ្ញុំចង់ទិញផ្កាមួយបាច់ជូនគេ....អ៊ំ អត់ទេ! បួនបាច់តំណាងពេល៤ឆ្នាំដែលខ្ញុំបានខកខានមិនបានជូនគេ.....។

ខ្ញុំដកដង្ហើមយូរធូរចិត្តហើយបត់ឡានបកក្រោយ.....

«ទៅណា?!» គេសួរស្រួយៗ តែមនុស្សស្រីម្នាក់នេះនឹងស្ម័គ្រទៅតាមខ្ញុំគ្រប់ទីកន្លែងដែលខ្ញុំចង់នាំនាងទៅ បេះដូងខ្ញុំដឹងរឿងនេះច្បាស់។

«ទៅទិញផ្កា!» ខ្ញុំឆ្លើយក្លូរៗ.....

«អ្នកណាលក់ថ្មើរហ្នឹងអ្ហះ?!»

គេថាឱ្យខ្ញុំទាំងភ្នែកចិញ្ចាចពេញទៅដោយក្តីស្រឡាញ់.....ខ្ញុំញញឹម...បេះដូងនេះកក់ក្តៅដល់ហើយ! ខ្ញុំពិតជាចង់ឱបគេណាស់ គឺនឹកដល់ពេលដែលគេឱបខ្ញុំបង្អួតប្រុសស្អាតមុននេះក្នុងជណ្តើរយន្ត....«នេះសង្សាររខ្ញុំ!» ខ្ញុំចង់ឮគេនិយាយពាក្យនេះជានិច្ច....ចង់ឮរហូតហើយឱបខ្ញុំដូចកាលពីនៅជាន់ខាងលើ...

នៅពេលដែលតណ្ហារលត់ទៅហើយមនុស្សពីរនាក់នៅតែមិនរបេះចេញពីគ្នា វាជាស្នេហាពិត! មេដៃកនេះនឹងបង្កើតឈ្មោះថ្មីមកឱ្យពួកយើងថា«គូស្វាមីភរិយា»

ម៉ាក់ខ្ញុំមិនដឹងជាសប្បាយចិត្តយ៉ាងណាទេបើខ្ញុំដឹកដៃគេទៅផ្ទះ  ញ៉ាំបាយនៅផ្ទះយើងក្នុងយប់នេះ....?

ខ្ញុំលូកដៃទៅក្តោបលើម្រាមទន់ៗរបស់នាង.....ពេលខ្ញុំងាកទៅឃើញកន្និកាឈ្ងោកមុខញញឹម...«មិញនេះនៅខាងលើ  បើគេទៅជាមួយម្នាក់នោះមែន  ខ្ញុំយប់នេះទៅអង្គុយផឹកaloneម្នាក់ឯងដូចកាលពីគេDating ពី៤ឆ្នាំមុនទៀតមិនខាន!»។

ខ្ញុំគិតបែបនេះក្នុងចិត្តស្ងាត់ៗ ទាំងសម្លឹងគេមិនដកភ្នែកចេញដូចជាប់ការ.....

«រៀបការជាមួយគ្នាបានអត់?!»

ខ្ញុំសួរគេថ្នមៗ.....

«ណ៎ា....បើនៅស្រឡាញ់!»

**ចប់**